# ក្រុមមេធាវីសឹរទ្ធិ

# របាយការណ៍សិក្ខាសាលា

## ស្តីអំពី

## ការដោះស្រាយវិវាទមូលដ្ឋានតាមប្រព័ន្ធច្បាប់-តួនាទីរបស់ក្រុមប្រឹក្សានៃរដ្ឋបាលតាមថ្នាក់ក្រោមជាតិ




ខេត្តរតនគិរី ថ្ងៃទី ២៩-៣០ ខែ មិថុនា ឆ្នាំ ២០១០

## មាតិកា

**ចំណងជើង** **ទំព័រ**


មាតិកា i

អារម្ភកថា ii

ខ្លឹមសារសង្ខេប iii

**ផ្នែកទី ១ : ចំណាប់អារម្មណ៍របស់ប្រធានក្រុមមេធាវីសិទ្ធិ និង ក្រុមប្រឹក្សាខេត្ត ១-១១**

ចំណាប់អារម្មណ៍របស់កញ្ញាមេធាវី អ៊ិត មធុរ៉ា ប្រធានក្រុមមេធាវីសិទ្ធ ១

ចំណាប់អារម្មណ៍របស់ឯកឧត្តម មួង ប៉យ ប្រធានក្រុមប្រឹក្សាខេត្តរតនគិរី ៣

ចំណាប់អារម្មណ៍របស់ឯកឧត្តម ជ័យ សាយឿន សមាជិកក្រុមប្រឹក្សាខេត្តរតនគិរី ៦

**ផ្នែកទី ២ : បទបង្ហាញរបស់លោក វ៉ាន់ និមល**

**ផ្នែកទី ៣ : បទបង្ហាញរបស់លោកស្រីមេធាវី សាត ធីតា**

**ផ្នែកទី ៤ : បទបង្ហាញរបស់លោកមេធាវី អ៊ឹម ផាន់ណា**

**ផ្នែកទី ៥ : លទ្ធផល នៃ អង្គសិក្ខាសាលា ១២-១៧**

**ផ្នែកទី ៦ : ការវាយតំលៃ នៃ អង្គសិក្ខាសាលា ១៨-២២**

**ឧបសម្ព័ន្ធ ២៣**

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា បានធ្វើកំនែទម្រង់ប្រព័ន្ធវិមជ្ឈការ និង វិសហមជ្ឈការរបស់ខ្លួនដើម្បីធានានូវការគោរពលទ្ធិប្រជាធិបតេយ្យ និង កាត់បន្ថយភាពក្រីក្រ។ ជាមួយការកំនែទម្រង់នៃប្រព័ន្ធវិមជ្ឈការនេះ ព្រះរាជាណាចក្រកម្ពុជាបានបង្កើតនូវច្បាប់ជាច្រើនដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ឆ្នាំ ២០០១ ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ ២០០២ និង ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឆ្នាំ ២០០៨ ក្នុងគោលដៅដើម្បីធានាអោយមានការអនុវត្តន៏នូវប្រព័ន្ធវិមជ្ឈការ និង វិសហ មជ្ឈការប្រកបដោយប្រសិទ្ធភាព។

ជាការពិតការអនុវត្តន៏ប្រព័ន្ធវិមជ្ឈការ និង វិសហមជ្ឈការនៅកម្ពុជាជិតមួយទសវត្សន៏បានបង្ហាញអោយឃើញនូវសញ្ញាណវិជ្ជមានជាច្រើន នៃ ការអភិវឌ្ឍន៏នូវមូលដ្ឋានដោយមានការចូលរួមពីសហគមន៏មូលដ្ឋាន។ក៏ប៉ុន្តែទន្ទឹមនឹងភាពវិជ្ជាមាននេះការសិក្សាស្រាវជ្រាវ[1] ក៏បង្ហាញផងដែរថាបញ្ហាជាច្រើនដែលកើតត្រូវបានប្តឹងទៅដល់ក្រុមប្រឹក្សា នៃ រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីជួយសំរបសំរួលផ្សះផ្សារដោះស្រាយដូចជាបញ្ហាអំពើហឹង្សាក្នុង គ្រួសារ បញ្ហាវិវាទអាពាហ៏ពិពាហ៏ និង គ្រួសារ និង បញ្ហាវិវាទដីធ្លីជាដើម។

ដូចនេះ ការពង្រឹងសមត្ថភាពបន្ថែមទៅដល់មន្ត្រីថ្នាក់មូលដ្ឋានពាក់ព័ន្ធនឹងវិស័យច្បាប់ជាពិសេស ច្បាប់ពាក់ព័ន្ធទៅនឹងអំពើហឹង្សាក្នុងគ្រួសារ ច្បាប់អាពាហ៏ពិពាហ៏ និង គ្រួសារ និង ច្បាប់ពាក់ព័ន្ធនឹងដីធ្លីជាផ្នែកមួយសំខាន់ដើម្បីធានាអោយការដោះស្រាយវិវាទថ្នាក់ មូលដ្ឋានតាមរយៈការផ្សះផ្សារប្រកបដោយប្រសិទ្ធិភាព។

ភ្នំពេញ ថ្ងៃទី.................ខែ..................ឆ្នាំ ២០១០

ក្រុមមេធាវីសិរីទ្ធ

[1] Caroline Rusten, Kim Sedara,Eng Netra and Pak Kimchoeun, *The Challenges Decentralization Design in Cambodia* , Cambodia Development Resources Institute(CDRI), Phnom Penh October 2004, Page 126-127

# ខ្លឹមសារសង្ខេប

របាយការណ៍នៃអង្គសិក្ខាសាលាស្តីអំពី **ការដោះស្រាយវិវាទមូលដ្ឋានតាមប្រព័ន្ធច្បាប់៖ តួនាទីរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ** ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីអោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់យល់ដឹងអំពី ប្រភេទនៃវិវាទមូលដ្ឋានដែលក្រុមប្រឹក្សាមានសិទ្ធិក្នុងការដោះស្រាយតាមរយៈការផ្សះផ្សារ និងសញ្ញាណទូទៅនៃច្បាប់ពាក់ព័ន្ធនឹងវិវាទមូលដ្ឋានដូចជាៈ ច្បាប់ដីធ្លី ច្បាប់អាពាហ៏ពិពាហ៏គ្រួសារ ច្បាប់អំពើហឹង្សាក្នុងគ្រួសារ ច្បាប់ឯកពន្ធភាពជាដើម ។

របាយការណ៍នេះ ត្រូវបានរៀបចំ និង បែងចែកជា ៤ ផ្នែក រួមមាន :

១. ចំណាប់អារម្មណ៏របស់ប្រធានក្រុមមេធាវីសីរីទ្ធ ចំណាប់អារម្មណ៍ប្រធានក្រុមប្រឹក្សាខេត្តរតនគីរី និងសមាជិកក្រុមប្រឹក្សាខេត្តរតនគីរី

២. បទបង្ហាញរបស់វាគ្មិន

៣. លទ្ធផល នៃ អង្គសិកាសាលា

៤. ការវាយតំលៃ នៃ អង្គសិក្ខាសាលា

ចំពោះបទបង្ហាញរបស់វាគ្មិន យើងខ្ញុំបានធ្វើការដកស្រង់នូវបទបង្ហាញ និង ការពន្យល់របស់វាគ្មិនទាំងបីរូបពាក់ព័ន្ធទៅនឹងចំនុចសំខាន់ ៧ នៃការដោះស្រាយបញ្ហាមូលដ្ឋានតាមប្រព័ន្ធច្បាប់ : តួនាទីរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា :

១. សញ្ញាណអំពីច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់ បង្ហាញដោយលោក វ៉ាន់ និមល

២. ច្បាប់ភូមិបាល និងការដោះស្រាយវិវាទដីធ្លី បង្ហាញដោយលោកស្រីមេធាវី សាត ធីតា

៣. ការដោះស្រាយជំលោះគ្រួសារ ដោយយោងតាមច្បាប់អាពាហ៏ពិពាហ៏ និងគ្រួសារ បង្ហាញដោយលោកមេធាវី អ៊ឹម ផាន់ណា

បន្ថែមលើនេះ របាយការណ៍ នៃអង្គសិក្ខាសាលានេះ ក៏បានភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធដើម្បីផ្តល់ភាពងាយដល់អ្នកអានទាំងអស់ អាចយល់កាន់តែច្បាស់អំពីការដោះស្រាយវិវាទមូលដ្ឋានតាមប្រព័ន្ធច្បាប់ ។

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ ២០១០

ក្រុមមេធាវីសីរីទ្ធ

# ផ្នែកទី ១

# ចំណាប់អារម្មណ៍របស់ប្រធាន
# ក្រុមមេធាវីស៍រខ្មែរ
# ប្រធានក្រុមប្រឹក្សាខេត្ត និង
# សមាជិកក្រុមប្រឹក្សាខេត្តរតនគិរី

# ចំណាប់អារម្មណ៍ កញ្ញា អ៊ិត មធុរ៉ា ប្រធានគ្រប់គ្រងក្រុមមេធាវីសិរីវឌ្ឍ




ជាបឋម នាងខ្ញុំសូមគោរព ឯកឧត្តម **មួង ប៉ុយ** ប្រធានក្រុមប្រឹក្សាខេត្តរតនគិរី ដែលបាន អញ្ជើញជាកិត្តិយសចូលរួមបើកអង្គសិក្ខាសាលានេះ។ សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលមានវត្តមាននៅទីនេះ។ ថ្ងៃនេះនាងខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលក្រុម មេធាវីសិរីវឌ្ឍ មានកិត្តិយសបានទទួលការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់។ ក្រុមមេធាវីសិរីវឌ្ឍ ជាក្រុមមេធាវីដែលបានបង្កើតឡើងក្នុងក្របខណ្ឌគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈសេរី និង ឯករាជ្យ ចូលរួមក្នុងវិស័យយុត្តិធម៌។ ដោយស្វែងយល់ថា ក្រុមប្រឹក្សា ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មានតួនាទីយ៉ាងសំខាន់ក្នុងការលើកកំពស់យុត្តិធម៌សង្គម ដែលនាងខ្ញុំ អាចលើកជាឧទាហរណ៍យ៉ាងសង្ខេបដូចជា:

- អាជ្ញាធរស្រុក ខេត្ត ជាតួអង្គដែលអាចមានខ្លះបានក្នុងការសម្រុះសម្រួលបញ្ចប់វិវាទរវាងភាគីនៅក្នុងការដោះស្រាយវិវាទដីធ្លី។
- ជួយទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។ល។

តាមរយៈសិក្ខាសាលានេះ នាងខ្ញុំសង្ឃឹមថា ក្រុមមេធាវីសិរីវឌ្ឍ ក៏ដូចជាមេធាវីទូទាំងប្រទេស អាចទទួលបានឱកាសដើម្បីចូលរួមលើកតម្កើង យុត្តិធម៌ ក៏ដូចជាសេដ្ឋកិច្ចសង្គមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ។ នាងខ្ញុំសូមអនុញ្ញាតិជំរាបជូនផងដែរថា លទ្ធផលដែលបានពីសិក្ខាសាលានេះ នឹងផ្ញើរជូនក្រសួងមហាផ្ទៃផងដែរ។ ថ្វីត្បិតតែ ក្រុមមេធាវីសិរីវឌ្ឍជាអ្នកសម្របសម្រួលពិធីនេះមែនពិត ប៉ុន្តែនាងខ្ញុំជឿជាក់ថាលទ្ធផលល្អដែលនឹងអាចទទួលបានគឺដោយសារតែមានការចូលរួមជជែកពិភាក្សាវែកញែកអោយ បានស៊ីជំរៅពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់។

ដូចនេះ នាងខ្ញុំសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី ចូលរួមការជជែក ពិភាក្សាក្នុងសិក្ខាសាលាអោយបានច្រើនតាមដែលអាចធ្វើទៅបាន។ នាងខ្ញុំ សូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ដែលមានវត្តមាននៅទីនេះ។ ជាទីបញ្ចប់ នាងខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ គ្រប់ពេលវេលា។ សូមអរគុណ!

## ចំណាប់អារម្មណ៍ ឯកឧត្តម មួង ប៉ុយ ប្រធានក្រុមប្រឹក្សាខេត្តរតនគិរី



ជាបឋម ខ្ញុំបាទសូមគោរព កញ្ញា អ៊ិត មធុរ៉ា ប្រធានក្រុមមេធាវីសីរីទ្ធ ។ សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី ក្រុមប្រឹក្សាខេត្ត ស្រុក ទាំងអស់ជាទីគោរព ។ ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលមានកិត្តិយសណាស់ដែលបានចូលរួមប្រកាស បើកអង្គសិក្ខាសាលា ស្តីអំពី ការដោះស្រាយវិវាទមូលដ្ឋានតាមប្រព័ន្ធច្បាប់ : តួនាទីរបស់ក្រុមប្រឹក្សា នៃ រដ្ឋបាលថ្នាក់ក្រោមជាតិនាឱកាសនេះ ដែលសិក្ខាសាលានេះរៀបចំដោយក្រុមមេធាវី សីរីទ្ធ ដោយបានការយល់ព្រមអនុញ្ញាតិដោយក្រសួងមហាផ្ទៃដែលបញ្ជាក់នៅក្នុងស.ជ.ណ ចុះខែ ឧសភា ឆ្នាំ ២០១០ អោយមានការប្រារព្ធវគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ។

ពិតណាស់ក្រោយឆ្នាំ ១៩៧៩ យើងបានចូលប្រឡូកក្នុងកិច្ចការនយោបាយ ក៏ដូចជាកិច្ចការសង្គមជា ច្រើនមកហើយ អញ្ចឹងហើយ យើងគិតថាឥលូវនេះ ម៉េចបានខាងមេធាវី លោកយកតែសមាជិកក្រុម ប្រឹក្សាឱ្យចូលរួមវគ្គសិក្ខាសាលា? ហើយមិនអញ្ជើញខាងមន្ត្រីរាជការនៅក្នុងក្របខណ្ឌ? អញ្ចឹងមានន័យថាយើងចេញពីក្របខណ្ឌរួចទៅហើយ ព្រោះយើងចូលនិវត្តន៍ទៅហើយ តែក៏មានឯកឧត្តម លោកជំទាវ លោក លោកស្រី ខ្លះគាត់ឋិតនៅក្នុងក្របខណ្ឌនៅឡើយ ខ្លះទៀតចូលនិវត្តន៍ហើយ ។ ករណីខ្លះទៀត គាត់បានចេញពីក្របខណ្ឌទៅហើយមានន័យថាចូលនិវត្តន៍ ។ បើយើងនិយាយពីបញ្ហាដែលទាក់ទង នឹង បញ្ហាមូលដ្ឋាន ការដោះស្រាយបញ្ហានូវមូលដ្ឋានយើងធ្លាប់ជួបប្រទះមកហើយ ខ្ញុំសូមលើកជាឧទាហរណ៍ តែខ្ញុំសូមមិនលើកយកច្បាប់មកនិយាយទេ ទុកឱ្យខាងមេធាវីគាត់ផ្តល់ឱ្យយើងដើម្បីធ្វើការពិភាក្សា ។ ខ្ញុំឧទាហរណ៍មួយ ក្រៅប្រធានបទបន្តិច តែវាទាក់ទីងនឹងការដោះស្រាយវិវាទមូលដ្ឋាន ប្រជាជនចង់លក់គោ របស់គាត់ ហើយអ្នកទិញទៅដឹកស្រាប់តែតាមផ្លូវទៅជួបជាមួយប៉ុស្តិ៍រដ្ឋបាលនគរបាលភូមិ នគរបាលភូមិថា មានការដឹកគោច្រឡំ ឬក៏លួចគេហើយក៏មានការប្តឹងផ្តល់ដល់ប៉ូលីសអធិការដល់ស្រុក ដល់កងរាជអាវុធហត្ថ ស្រុក អញ្ចឹងគេក៏យកកូនគោនោះមកប្តឹងផ្តល់ដល់បញ្ជាការអាវុធហត្ថខេត្ត ។ អញ្ចឹងប្រជាពលរដ្ឋគាត់ខឹង សម្បារ គាត់ថាការដោះស្រាយដោយអយុត្តិធម៌ ហើយគាត់ក៏នាំគ្នាប្រហែល ៣០-៤០ នាក់ដល់ផ្ទះ សួររកហេតុផល ហើយខ្ញុំក៏មិនទាន់ដឹង

ថាមេភូមិ ស្រុក គាត់ ដោះស្រាយនោះដល់កំរិតណាដែរ? ព្រោះពេល នោះការអនុវត្តវិមជ្ឈការ វិសហមជ្ឈការ វាមានពីរអាណត្តិមកហើយ ប៉ុន្តែការដោះស្រាយរបស់យើង វាមិនទាន់មាននៅថ្នាក់ឃុំនៅឡើយទេ ។ អញ្ចឹងក្រុមប្រឹក្សាឃុំធ្វើអ្វី? តែសួរចុះសួរឡើង សុទ្ធតែយើង និយាយបានថាអយុត្តិធមិ និយាយជាសាមញ្ញទៅចុះ យើងនិយាយថា ធម្មតា អ្នកណាមានលុយ អ្នកនោះឈ្នះ អ្នកណាគ្មានលុយ ចាញ់ យើងនិយាយដូច្នេះចុះ! អញ្ចឹងយើងក៏នាំគ្នាទៅដោះទាំងថ្ងៃ ហើយហៅទាំង អាវុធហត្ថខេត្ត ស្រុក ទាំងអធិការ ស្នងការមកជជែកគ្នា ព្រោះយើងមិនទាន់ថាអ្នកណាខុសត្រូវទេ ហើយខ្ញុំថាឥលូវធ្វើតាមខ្ញុំ យកកូនគោនោះទៅវិញ ដឹកដាក់ឡានទៅវិញ ហើយញែកហ្វូងមេគោនោះជាពីរ ដាក់សងខាងផ្លូវ ហើយលែងកូនគោនោះឱ្យទៅរកមេវា ព្រោះវាស្គាល់ មេវាហើយ គោនោះក៏ទៅរកមេវា។ អញ្ចឹងយើងដោះស្រាយបញ្ហានេះដោយតាមទីតិវិធីប្រពៃណី ប៉ុន្តែអត់បានធ្វើតាមច្បាប់។ ដូច្នេះបានឈ្នះតាមហ្នឹង។ បើនិយាយតាមឈ្នះ បើមិនធ្វើតាមអាហ្នឹង វាឈ្នះតាម អ្នកណាមានវោហារលើសគេនៅភូមិ ឬនៅកន្លែងណាមួយ សហគមន៍ណាមួយ គឺ អ្នកនោះឈ្នះហើយ ឈ្នះទៅលើអ្នកដែលអត់ចេះនិយាយ បើនិយាយពីរឿងនេះ ជនជាតិខាងរតនគីរី មិននិយាយពី ខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគីរី ខ្ញុំមិនដឹងទេ តែនៅក្នុងខេត្តរតនគីរី គាត់អត់ចេះភាសាខ្មែរ ហើយអត់ចេះច្បាប់ផង តើត្រូវធ្វើដូចម្តេច? នេះជាបញ្ហា ដែលខ្ញុំចង់លើកជាឧទាហរណ៍តាមបទពិសោធន៍ក្នុងការដឹកនាំកន្លងមក ព្រោះយើងសុទ្ធតែជាអ្នកដឹកនាំហើយ ប៉ុន្តែរឿងច្បាប់យើងនៅមិនទាន់យល់នៅអ្វីដែលពាក់ព័ន្ធនឹងការងាររបស់យើងនៅឡើយ ។ កន្លងទៅ យើងមិនទាន់មានច្បាប់អាពាហ៍ពិពាហ៍នឹងគ្រួសារ ស្រលាញ់គ្នា ចាស់ទុំធ្វើការសម្របសម្រួលគ្នាទៅ ចរចាគ្នា រៀបការហើយ ។ តែប៉ុន្មានឆ្នាំនេះ យើងបានធ្វើការបំពេញឯកសារ បែបបទអត្រានុកូលដ្ឋាន សំបុត្រ អាពាហ៍ពិពាហ៍មួយចំនួន ។ ព្រោះគាត់គិតថារឿងនេះមិនសូវសំខាន់ទេ តែយើងព្យាយាមពន្យល់ពួកថា បើធ្វើទៅតាមច្បាប់ពេលមានវិបត្តិ វាងាយស្រួលដោះស្រាយ ។

ទន្ទឹមនឹងការលើឡើងមកខាងលើនេះ ក្នុងនាមប្រធានក្រុមប្រឹក្សាខេត្តរតនគីរី ខ្ញុំសូមវាយតំលៃខ្ពស់ចំពោះវគ្គសិក្ខាសាលា និងសូមថ្លែងអំណរគុណជាអតិបរមាចំពោះក្រុមមេធាវីសិរីទ្ធ និងសូមថ្លែងអំណរគុណជាអតិបរមា ចំពោះវត្តមានចូលរួមសិក្ខាសាលារបស់សមាជិកក្រុមប្រឹក្សាខេត្តស្ទឹងត្រែង ក្រចេះ និងមណ្ឌលគីរី ក៏ដូចជាក្រុមប្រឹក្សាសមាជិកក្នុងខេត្ត ដែលឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានចំណាយពេលវេលាដ៏សំខាន់របស់ផងខ្លួន ក្នុងការអញ្ជើញចូលរួមក្នុងវគ្គសិក្ខាសាលានេះ ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរបវរប្រសើរ ជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា និងគណៈអធិបតី ទាំងអស់ សូមមានសុខភាពល្អ កំលាំងមាំមួន និងប្រកបដោយពុទ្ធពរ ទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។ ជូសមុខឱ្យគណៈអធិបតី ខ្ញុំសូមប្រកាសបើកវគ្គសិក្ខាសាលាចាប់ពីពេលនេះតទៅ។ សូមអរគុណ!

## ចំណាប់អារម្មណ៍ ឯកឧត្តម ជ័យ សាយឿន សមាជិកក្រុមប្រឹក្សាខេត្តរតនគីរី



ជាបឋម ខ្ញុំសូមគោរពអស់កញ្ញា អ៊ិត មធុរ៉ា ប្រធានក្រុមមេធាវីសីរីទ្ធ ។ សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកា គណៈភិបាលខេត្ត ជាទីនឹករលឹក និង អស់ លោក លោកស្រី ជាសមាជិក សមាជិកា ក្រុមប្រឹក្សាស្រុក ក្រុង ឃុំ សង្កាត់ នៃខេត្តទាំង ៤ ជាទីនឹករលឹក។ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាមន្ត្រីទទួលបន្ទុកប្រព័ន្ធយុត្តិធម៌ និង អ្នកពាក់ព័ន្ធទាំងអស់ជាទីគោរព និង ជាទីនឹករលឹក។ ជាការពិត ចាត់ទុកថាជាកិត្តិយសសម្រាប់ខេត្តរតនគីរី ក៏ដូចជាសម្រាប់ខេត្តទាំង ៤ នៅភូមិភាគឥសាន ដែលរួមមាន ខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរីដែលត្រូវក្រុមមេធាវីសីរីទ្ធ ដែលដឹកនាំដោយកញ្ញា អ៊ិត មធុរ៉ា ប្រធានក្រុមមេធាវីសីរីទ្ធបានផ្តល់កិត្តិយស និងលើកទឹកចិត្ត ក៏ដូចជាចែករំលែកនូវចំណេះដឹងទាក់ទងនឹងការដោះស្រាយវិវាទក្នុងមូលដ្ឋាន ពាក់ព័ន្ធនឹងច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ច្បាប់ឯកពន្ធភាព និងអំពើហិង្សាក្នុងគ្រួសារ និងដីធ្លី ។

ជាការពិតណាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សុទ្ធតែជាអ្នកធ្លាប់មានបទពិសោធន៍ក្នុងវិជ្ជាជីវៈជាអ្នករដ្ឋបាល និងជាអ្នកទទួលខុសត្រូវក្នុងប្រព័ន្ធយុត្តិធម៌ ជាពិសេសគោរពច្បាប់ទំលាប់ការងារក្នុងមូលដ្ឋាន។ សិក្ខាសាលា នាឱកាសនេះ ក៏ចាត់ទុកថា ជាការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលយ៉ាងសំខាន់ ដើម្បីឱ្យថ្នាក់រដ្ឋបាលក្រោមជាតិ កាន់តែទទួលបាននូវចំណេះដឹងថ្មីៗថែមទៀត សម្រាប់បង្កលក្ខណៈឱ្យសិក្ខាកាមស្តីពីការដោះស្រាយវិវាទតាមមូលដ្ឋានបានប្រព្រឹត្តទៅដោយរលូន ។ នេះជាការឆ្លុះបញ្ចាំងនូវប្រព័ន្ធគ្រប់គ្រងតាមលទ្ធិប្រជាធិបតេយ្យ និងមានការចូលរួម។ ជាការពិតហើយ ការដឹកនាំប្រទេស កាលណាផែនការអនុវត្តត្រូវបានទទួលការគាំទ្រ និងដំណើរប្រតិបត្តិ បញ្ហាវិវាទ បញ្ហាទំនាស់តែងតែកើតមាន នេះគឺជាកត្តាសន្យានុម័ត តែអ្វីដែលយើងចាប់អារម្មណ៍ គឺចំណេះដឹងរបស់អ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកទទួលខុសត្រូវក្នុងស្ថាប័នប្រកបដោយភាពឈ្លាសវៃ និងយល់ដឹងយ៉ាងទូលំទូលាយពីបញ្ហាទាំងនេះ។ ការដោះស្រាយទំនាស់ ខ្ញុំជឿថាមិនប្រាកដថា មូលដ្ឋានមួយមានចរិតលក្ខណៈដូចមូលដ្ឋានមួយទៀតនោះទេ ស្ថានភាពដែលនៅតំបន់

ស្ថានភាពភូមិ ឆ្លុះបញ្ចាំងពីចិត្តគំនិតដាច់ដោយឡែកពីគ្នា ឧទាហរណ៍ ស្ថានភាពជីវភាព ប្រពៃណី វប្បធម៌ អ្នករស់នៅតាមតំបន់ វាលរាប អាចមានវាអាចមានលក្ខណៈខុសប្លែកពី អ្នករស់នៅតំបន់ខាងលិចដែលជាខេត្តមានចំការកៅស៊ូ ។ ដូច្នេះ សិក្ខាសាលានេះ គឺឆ្លើយតបចំពោះខេត្ត ដែលនៅភូមិភាគឥសានដែលជួបការលំបាក ។ មិនមែនថា យើងបក្សពួកទេ ស្ថាប័នយើងមានធនធាន មានសមត្ថភាពដោះស្រាយតាមនីតិវិធីអស់ហើយ ក៏ប៉ុន្តែអ្នកទទួលយកការសម្របសម្រួល ឬអំណាចនីតិវិធី គាត់ទទួលយកអត់បាន ករណីខ្លះដូចជាក្នុងសិក្ខាសាលាស្តីពីការចុះបញ្ជីដី សហគមន៍ជនជាតិដើមភាគតិច គាត់បានសួរថា ចុះបើខ្ញុំជាជនជាតិ បើខ្ញុំអត់ចេះច្បាប់ ពេលដែលខ្ញុំកាន់កាប់ដីរដ្ឋ ខ្ញុំមានទោសក៏អី? ចំលើយគឺ ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិស្មើគ្នាទាំងក្នុងជីវភាពទាំងចំពោះមុខច្បាប់ ។ ទោះបីជាដំណើរការដោះស្រាយវិវាទ សម្របសម្រួលវិវាទក្រៅប្រព័ន្ធតុលាការ ក៏វានៅតែផ្អែកលើច្បាប់ជាភស្តុតាងគតិយុត្តិដែលត្រូវបានសភាអនុម័ត សភាដែលជាតំណាងប្រជាពលរដ្ឋ និងត្រូវផ្តល់សច្ចាប័នដោយព្រះមហាក្សត្រ។ ទោះបីជា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមមណ្ឌលយុត្តិធម៌សហគមន៍ ឬហៅថា មណ្ឌលយុត្តិធម៌ នៅខេត្តរតនគីរី មានមណ្ឌលយុត្តិធម៌ពីរ គឺ មួយនៅស្រុកបានលុង និងស្រុកអូយ៉ាដាវមួយ ។ ការដោះស្រាយវិវាទតាមមណ្ឌលយុត្តិធម៌ គឺគាត់ទទួលបាននូវការកាត់បន្ថយនូវភាពស្មុគ្រស្មាញមួយចំនួននៅ ការទទួលខុសត្រូវរបស់ស្ថាប័នតុលាការ ប៉ុន្តែមិនមែនសុទ្ធតែត្រូវបានដោះស្រាយនៅមណ្ឌលយុត្តិធម៌ទេ ប្រសិនបើប្រព្រឹត្តទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ ឬឯកសារយថាភូតផ្សេងៗដែលអាចយកជាមូលដ្ឋានបាន។ ហើយបច្ចុប្បន្ននេះខេត្តទាំង ៤ យើងទទួលស្គាល់ថា បញ្ហាអំពើហិង្សាក្នុងគ្រួសារនៅតែមាន អំពើហិង្សា ក្នុងគ្រួសារ វាអាចកើតមកពីខ្វះការយោគយល់ផ្លូវចិត្តគ្នារវាងប្តី និងប្រពន្ធ រវាងមេដឹកនាំគ្រួសារនីមួយៗ ជាមួយនឹងកូនក្នុងបន្ទុក ឬក៏ខ្វះការអត់អោន ឬមួយផ្នែកទៀត កើតឡើងដោយចេតនាដែលជនល្មើសបង្កឱ្យកើតឡើង ដូចជាមកពីករណីក្បត់ ប៉ុន្តែមានករណីមួយចំនួនទៀតគ្រាន់តែសង្ស័យថា ក្បត់ ទៅប្រព្រឹត្ត ធ្វើទណ្ឌកម្មលើគេដែរ ។ ជួនកាលដំណើររឿងដើម គឺជារឿងរដ្ឋប្បវេណី ក៏ប៉ុន្តែការសម្រេចចិត្តរហ័សពេក ដើម្បីឆ្លើយតបនឹងហិង្សាផ្លូវចិត្ត គាត់បានប្រព្រឹត្តបទល្មើសបង្កឱ្យទៅជារឿងព្រហ្មទណ្ឌ ។ យប់ហើយ ខែភ្លឺ ខេត្តរតនគីរី ទំលាក់លីផ្លាក់មានករណីមួយ នៅសោមសារី អាហ្នឹង គឺស្ថានភាពយកអបិយជំនឿមក លេងសើច អាងកាំភ្លើង ហើយថាបើកាំភ្លើងភ្ជង់អ្នកណា អ្នកហ្នឹងក្រមួយជីវិត ។ គ្រាន់តែអបិយជំនឿប៉ុណ្ណឹង បង្កជាការបាញ់គ្នាស្លាប់ ធ្វើរបាយការណ៍ទៅអធិការដ្ឋានឱ្យចាត់ការតាមនីតិវិធី ពេលយកជនសង្ស័យបញ្ជូន ទៅតុលាការ ប៉ុន្តែចាស់ទុំប្រពៃណីរបស់គាត់ថាទុកឱ្យគាត់កាត់សេចក្តីវិញ ។ កន្លែងហ្នឹងហើយ ដែលរឿង អបិយជំនឿ

រឿងរដ្ឋប្បវេណី បង្កជារឿងព្រហ្មទណ្ឌ ។ ពាក់ព័ន្ធមួយទៀត រឿងទំនាស់ដីធ្លី បញ្ហាដីធ្លីសព្វថ្ងៃ ជាបញ្ហាដែលប្រឈមសម្រាប់រដ្ឋបាលមូលដ្ឋាន បច្ចុប្បន្នយើង តំណាងឱ្យរាជរដ្ឋាភិបាលក្នុងការអនុវត្តកំណែទំរង់រដ្ឋបាល។ រដ្ឋបាលមួយ មានទំរង់ពីរៈ ថ្នាក់ស្រុក ថ្នាក់ខេត្ត ថ្នាក់ឃុំ មានក្រុមប្រឹក្សាឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត មានក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ជួនកាលគណៈអភិបាលគាត់សម្រេចផ្តល់អ្វីមួយ ផ្តល់កិច្ចសន្យា ឬសេចក្តីសម្រេចផ្តល់សេចក្តីទុកចិត្តឱ្យនរណាមួយ ដល់តែមានទំនាស់កើតឡើងអ្នកណាអ្នកទទួលខុសត្រូវ? ក្រុមប្រឹក្សា គឺជាអ្នកមាន ករណីយភាពជាមួយប្រជាពលរដ្ឋ ពីព្រោះប្រជាពលរដ្ឋជាអ្នកបោះឆ្នោតឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ជាអ្នកបោះឆ្នោតផ្តល់សេចក្តីទុកចិត្តឱ្យបេក្ខភាពរបស់ក្រុមប្រឹក្សាស្រុក ក្រុង និងខេត្ត ។ អញ្ចឹងក្រុមប្រឹក្សា ត្រូវទទួលខុសត្រូវដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ និងជាមួយរាជរដ្ឋាភិបាល ។ ឯអភិបាលខេត្ត គាត់មានករណីយភាពជាមួយប្រជាពលរដ្ឋ និងទទួលខុសត្រូវដោយផ្ទាល់ជាមួយក្រសួងមហាផ្ទៃ ។ អញ្ចឹងមិនមែន ក្រុមប្រឹក្សាអត់ការងារធ្វើ ជួនកាលការងារនៅការិយាល័យតិច តែអ្នកទទឹងរង់ចាំការឆ្លើយតបរបស់យើង គឺប្រជាពលរដ្ឋរបស់យើង អ្នកដែលគាំទ្រឱ្យយើងធ្វើជាសមាជិកសមាជិកា ក្រុមប្រឹក្សា គឺប្រជាពលរដ្ឋនេះហ្នឹងឯង។ អញ្ចឹងពេលទំនេរដែលយើងមិនសូវចូលការិយាល័យនៅស្រុក នៅខេត្ត មិនបានន័យថា ក្រុមប្រឹក្សាទាត់ខ្យល់នោះទេ ក៏ប៉ុន្តែទៅស្វែងយល់សេចក្តីត្រូវការទុកលំបាករបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ហើយក្រុមប្រឹក្សាជានិច្ចកាលត្រូវគោរពចក្ខុវិស័យរបស់ខ្លួន ដើម្បីផលប្រយោជន៍រួម តើមូលដ្ឋានណាត្រូវការអ្វីជាងគេ? ដើម្បីយកមកធ្វើការឆ្លុះបញ្ចាំងជាមួយគណៈអភិបាលពេលប្រជុំវិសាមញ្ញរបស់បង្វែរកម្មវិធីអភិវឌ្ឍជនបទ គំរោងនានា ដើម្បីឆ្លើយតបជាមួយប្រជាពលរដ្ឋ មិនបានទាញយកផលប្រយោជន៍សាធារណៈសម្រាប់សហគមន៍ និងប្រជាពលរដ្ឋ មកបំរើឯកជនទេ។ បើការឆ្លើយតបមិនបានតាមសំណូមពរ ឬមិនផ្តល់សេចក្តីសង្ឃឹមនាំឱ្យមានទំនាស់ផ្លូវចិត្ត ទំនាស់ផ្លូវចិត្តនេះឯងហើយដែលនាំឱ្យគាត់បាត់ជំនឿលើការគ្រប់គ្រងរបស់យើង។ ប្រសិនបើមិននៅការិយាល័យ ធ្វើការតាមមូលដ្ឋានឱ្យបានច្រើន ធ្វើការទទួលខុសត្រូវជាមួយប្រជាពលរដ្ឋ នេះជាការឆ្លើយតបចំពោះករណីយភាពជាមួយប្រជាពលរដ្ឋដោយផ្ទាល់ និងរាជរដ្ឋាភិបាល។ នៅខេត្ត នៅស្រុក រដ្ឋបាលមានទំរង់ពីរ គឺទំរង់ប្រតិបត្តិរបស់គណៈអភិបាល និងទំរង់បញ្ញត្តិ ។ ទំរង់បញ្ញត្តិ គឺ ក្រុមប្រឹក្សាឱ្យអ្នកឯងរៀបចំផែនការយកមកឆ្លងឱ្យក្រុមប្រឹក្សាអនុម័ត ក្រុមប្រឹក្សាអនុម័តដាក់ឱ្យអ្នកធ្វើ ហើយក្រុមប្រឹក្សាតាមដានវាយតំលៃ អញ្ចឹងរបាយការណ៍ឆ្លងខេត្ត របាយការណ៍របស់គណៈអភិបាល។ នេះជាការផ្គូផ្គង់របស់យើង រវាងអំណាចប្រតិបត្តិ និងបញ្ញត្តិ ។ ក្រុមប្រឹក្សាមិនមែន ជាអំណាចនីតិបញ្ញត្តិ ប៉ុន្តែជាអំណាចបញ្ញត្តិជា រដ្ឋបាលក្រោមជាតិ។

មួយវិញទៀត ត្រូវក្តាប់ឱ្យបាននូវបញ្ហា ដែលកើតមាននៅក្នុងមូលដ្ឋានរបស់យើង ខ្ញុំសង្កេតឃើញថា ជួនកាលដីខ្លះមានបញ្ហាទំនាស់កើតឡើងក្នុងមូលដ្ឋាន ប៉ុន្តែថ្នាក់ស្រុកអត់ដឹងក៏ថាបាន តែថ្នាក់ខេត្តដឹង បើដឹងដល់ខេត្ត គឺដឹងដល់រាជរដ្ឋាភិបាលហើយ មូលហេតុអ្វី? នេះហើយហៅថា ប្រជាធិបតេយ្យ រដ្ឋប្រជាធិបតេយ្យអញ្ចឹង ប្រជាធិបតេយ្យសេរីពហុបក្ស ។ មានភ្នាក់ងារកាសែត អ្នកយកព័ត៌មានខ្លះចុះដល់មូលដ្ឋាន ច្រើនជាងកម្មាភិបាលចុះមូលដ្ឋានទៀត។ ខ្ញុំប្រើពាក្យ កម្មាភិបាល គឺមន្ត្រីទទួលខុសត្រូវ មន្ត្រីទទួលខុសត្រូវមិនសូវចុះមូលដ្ឋានបានច្រើនដង ដូចអ្នកកាសែត ដូចអង្គការសង្គមស៊ីវិលទេ ។ តែអង្គការសង្គមស៊ីវិលខ្លះ គាត់ឆ្លៀតឱកាសដើម្បីប្រាប់បញ្ហាឱ្យបានច្រើន វាយប្រហាររដ្ឋបាលយើងវិញថា យើងអសមត្ថភាពគ្រប់គ្រង បានប្រជាជនយើងជួបបញ្ហាច្រើន ។ នេះជារឿងមួយដែលយើងគួរប្រុងប្រយ័ត្នបំផុត។ នេះជាបញ្ហាមួយដែលពាក់ព័ន្ធនឹងប្រធានបទការដោះស្រាយវិវាទមូលដ្ឋានតាមប្រព័ន្ធច្បាប់។ ពាក់ព័ន្ធនឹងដីធ្លីទាំងអស់គ្នា ចាប់អារម្មណ៍ថាសិក្ខាសាលាក៏បានលើកឡើងដែរ ។ ឧទាហរណ៍ជាក់ស្តែងមានមនុស្សម្នាក់ចង់បានដីភូមិ "ក" សុំឱ្យក្រសួងកសិកម្មគូផែនទីក្នុងភូមិ "ក" បានផែនទីទំហំដី ១២០០០ ហិចតា ឱ្យគណៈកម្មាធិការអន្តរក្រសួងចុះមកអង្កេត ទៅវាស់លេមលើម។ ភូមិខ្លះប៉ះចំដីចំការរបស់គាត់តែម្តង កន្លែងខ្លះទៀតក្លាយជាភូមិដ្ឋានបាត់ហើយ ហើយអាចជាដីកប់ខ្មោច ដីព្រៃអារក្សរបស់គាត់ ចុះបើអ្នកធំស៊ីញ៉េហើយ មើលសុំថាបើគាត់សុំ ១២០០០ ហិចតា ឱ្យតែ ២០០០-៣០០០ ហិចតាបានហើយ ដើម្បីកាត់បន្ថយទំនាស់ និងផលប៉ះពាល់អគ្រាកំនើនប្រជាពលរដ្ឋ បើគាត់សុំ ១០០០០ ហិចតា ចង់បាន ១០០០០ ឱ្យ ១០០០០ ចង់បាន ១២០០០ ឱ្យ ១២០០០ ឱ្យ ១០០០០ ក៏ច្រើនដែរ ឱ្យតែ ៣០%-៤០% បានហើយ។ យើងត្រូវត្រៀមដីសង្គមកិច្ច ត្រូវត្រៀមអត្រាកំនើនប្រជាពលរដ្ឋយើង ត្រូវត្រៀមកន្លែងណា ជាកន្លែងយថាហេតុ ។ ដីក្រុមហ៊ុន បើគាត់ដាំកៅស៊ូ បើឱ្យគោចូល គោជាន់កៅស៊ូខ្ទេចខ្ទីអស់ហើយ ។ អញ្ចឹងបានកន្លែងណាសំរាប់លែងគោ លែងក្របី ហើយបើថាកុំខ្វល់ឱ្យទៅក្រុមហ៊ុនទៅ មិនបានដាំដុះអីទេ នាំគ្នាក្លាយជាកម្មករ គេទាំងអស់ទៅ! មិនបាច់ធ្វើអីទេ ធ្វើកម្មករគេបានហើយ ។ កាលណាពាក្យថា កសិករគាត់មានឥស្សរភាព របស់គាត់ ធ្វើការ ៤-៥ ម៉ោង ៣-៤ ម៉ោងមកផឹកស្រា ហើយដេកធ្វើមិនដឹងហ្នឹងហៅថាដេកធ្វើចំការ តែបើធ្វើជាកម្មករគេ អាយុមិនទាន់ ១៨ ឆ្នាំ អត់គ្រប់អាយុ គេអត់យកទេ ដល់តែអាយុ ៦៥ ឆ្នាំ ប្រើមនុស្សចាស់ជរាអត់បាន ខុសច្បាប់ រំលោភកំលាំងពលរដ្ឋទៀត ។ អញ្ចឹង មួយគ្រួសារ ៨ នាក់ មិនប្រាកដថាមានកំលាំងពលកម្មពេញលេញ ៨ នាក់ទេ ។ អញ្ចឹងសូមជួយពិចារណាគ្នា ដើម្បីធ្វើករណីយភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ ។ អញ្ចឹងសំណូមពរ សូមគាំទ្រកម្មវិធីរបស់រាជរដ្ឋាភិបាល

ដើម្បីកុំឱ្យដី វាធ្លាក់ទៅក្នុងដៃឯកជន បើលក់ទិញ លក់ទិញ នឹងក្លាយជាដីឯកជន ប៉ុន្តែបើធ្វើសម្បទាន សេដ្ឋកិច្ច ដីនោះវានៅជារបស់រដ្ឋដដែល ប៉ុន្តែដីដែលនៅសល់ពីហ្នឹងយកទៅណា? យកទៅលក់? អត់លក់ទេ យើងត្រៀមសម្រាប់សម្បទានសេដ្ឋកិច្ច ត្រៀមសម្រាប់អត្រាកំនើនប្រជាពលរដ្ឋ សេចក្តីត្រូវការជាយថាហេតុ សម្រាប់ប្រជាជនយើង។ នេះជាសំណូមពររបស់ខ្ញុំ ។ ពាក់ព័ន្ធនឹងទំនាស់ដីធ្លី សូមថ្លែងអំណរគុណណាស់ដលល់ ក្រុមមេធាវីសីទ្ធ ដែលមានកញ្ញា អ៊ិត មធុរ៉ា ដែលបានបង្កលក្ខណៈបើកសិក្ខាសាលាចំគោលដៅដែលមាន បញ្ហាទំនាស់ដីធ្លីនេះឡើង អ្នកខ្លះលក់ដីឱ្យគេមួយសារហើយ តាមពិតដីនោះជាដីព្រៃទេ តែអត់ឃើញអ្នកណា មកមើល ក៏លក់បន្តទៀត អ្នកខ្លះលក់ ១ ហិចតា ១០០ ដុល្លា ៣-៤ឆ្នាំក្រោយមកដីឡើងថ្លៃ សុំថែមលុយ បើមិនថែមលុយទេ ផ្តិតមេដៃមួយភូមិយកដីវិញ ហើយសងលុយ ១ ហិចតា ១០០ ដុល្លាមកវិញ យើងមាន ខុសឯណា? យើងសងលុយវិញណ្តើរ! អ្នកខ្លះលក់ឱ្យគេហើយ ទារយកវិញ ហើយថាគេមកបោក ចុះបើគេប្តឹងថាអ្នកឯងត្រូវរំលោភកិច្ចសន្យា ធ្វើម៉េច? វាអាចអញ្ចឹងដែរ ដូច្នេះហើយទាមទារឱ្យប្រជាជន ក៏ដូចជាក្រុមប្រឹក្សាមានចំណេះដឹង បើម្នាក់ចេះដឹង ពីរបីនាក់ចេះដឹង បញ្ហាអាចកាត់បន្ថយបានហើយ ។ រឿងមួយទៀត ពាក់ព័ន្ធនឹងច្បាប់ឯកពន្ធភាព ខ្ញុំគាំទ្រទាំងស្រុងតែម្តង ពីព្រោះនេះបង្កឱ្យមានទំនាស់ក្នុង គ្រួសារមិនចេះចប់ បើយើងនិយាយឱ្យមែនទែនទៅ ទំនាស់ក្នុងគ្រួសារមិនមែនកើតមកពីខាងស្រីប្រច័ណ្ឌនោះ ទេ ជួនកាលយើងខូចដែរ ប្រសិនបើទំពុកមិនទៅភ្នៅវាមិនមកទេ។ ការពិតអារម្មណ៍មនុស្សចេះតែចង់ប្លែក ដ៏តែចេះតែចង់ប្លែក រឿងក៏វាចេះតែប្លែក១ទៅតាមហ្នឹងដែរ ដល់តែមានបញ្ហាកាន់តែធំឡើង១ កិត្តិយសរបស់ គ្រួសារយើង ក៏វាប៉ះពាល់ទៅតាមហ្នឹងដែរ មិនស្រួលកូនរត់ចោលលែងនៅជាមួយម៉ែឪ ទៅជាប្រព្រឹត្តអំពើ ផ្តេសផ្តាសពាក់ព័ន្ធគ្រឿងញៀន សេពគ្រឿងញៀន នេះជាបញ្ហា។

អញ្ចឹងជាថ្មីម្តងទៀត ក្នុងនាមក្រុមប្រឹក្សារតនគីរី ជូសមុខឱ្យរដ្ឋបាលខេត្ត សូមថ្លែងអំណរគុណដល់ កញ្ញាមេធាវី អ៊ិត មធុរ៉ា ប្រធានក្រុមមេធាវីសីទ្ធ និងក្រុមមេធាវីទាំងអស់ ដែលបានបង្កបរិយាកាសឱ្យមាន សិក្ខាសាលានេះ ថ្វីត្បិតតែមានរយៈពេលខ្លី ក៏ប៉ុន្តែខ្ញុំជឿជាក់ថាដោយសារ ឯកឧត្តម លោក លោកស្រី ធ្លាប់ មានបទពិសោធន៍ ហើយធ្លាប់បានអនុវត្តជាក់ស្តែងនៅក្នុងតំបន់នូវបញ្ហាដែលជួបជាញឹកញាប់។ ទោះបីជា ក្រុមប្រឹក្សាក្តី រដ្ឋបាលក្តី រដ្ឋបាលស៊ីវិលក្តីមិនមានអំណាចជម្រះ ក៏មានតួនាទីអប់រំ ដើម្បីកាត់បន្ថយនូវអំពើ ហិង្សា កាត់បន្ថយអំពើខុសឆ្គង បទល្មើសព្រហ្មទណ្ឌនានាដែលបង្កឡើងដោយចេតនាក្តី អចេតនាក្តីដែលជាទុន យ៉ាងធំសម្រាប់ខេត្តទាំង ៤ របស់យើង។

ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម និងអស់លោក ជាសមាជិកក្រុមប្រឹក្សាខេត្តទាំង ៤ ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលមានវត្តមាននាឱកាសនេះ ហើយខ្ញុំជឿជាក់ថាតាមរយៈខ្លឹមសារសិក្ខាសាលា និងការទទួលការពិភាក្សាយ៉ាងស៊ីជំរៅ ប្រកបដោយការយកចិត្តទុកដាក់នូវការពន្យល់ការបង្ហាញរបស់វាគ្មិនដ៏មានបទពិសោធន៍របស់ក្រុមមេធាវី ខ្ញុំជឿជាក់ថា ឯកឧត្តម អស់លោក ពិតជានឹងធ្វើករណីយភាពល្អ និងកាន់តែស៊ីជម្រៅជាមួយប្រជាពលរដ្ឋ ដើម្បីឆ្លើយតបនឹងកម្មវិធីកំណែទំរង់របស់រាជរដ្ឋាភិបាល និងសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្រុមមេធាវីទាំងអស់ ទទួលបាននូវផ្លែផ្កាត្រចះត្រចង់ក្នុងការបំពេញភារកិច្ចជូនរាជរដ្ឋាភិបាល ក៏ដូចជាក្នុងនាមជាដៃគូរបស់រាជរដ្ឋាភិបាលក្នុងការកំណែទំរង់ ក៏ដូចជាប្រកបដោយជោគជ័យ និងកិត្តិយសឧត្តុងឧត្តម និងក៏ដូចក្នុងផែនការលើកតំកើងកម្ពុជាក្នុងសាកលលោក និងសូមប្រកាសបិទអង្គសិក្ខាសាលា ចាប់ពីពេលនេះតទៅ ។ សូមអរគុណ!

# ផ្នែកទី ២

# បទបង្ហាញរបស់លោក

# ថ៉ាន់ និមល

# (សូមមើលឯកសារភ្ជាប់)



# ផ្នែកទី ៣

# បទបង្ហាញរបស់លោកស្រីមេធាវី

# សាត ធីតា

# (សូមមើលឯកសារដែលបានភ្ជាប់)



# ផ្នែកទី ៤

# បទបង្ហាញរបស់លោកមេធាវី

# អ៊ឹម ផាន់ណា

# (សូមមើលឯកសារដែលបានភ្ជាប់)



# ផ្នែកទី ៥

# លទ្ធផល

# នៃ

# អង្គសិក្ខាសាលា









## សំនួរ ចំលើយ

ក្នុងវគ្គសិក្ខាសាលានេះ សិក្ខាកាមទាំងអស់ត្រូវបានអនុញ្ញាតអោយសួរសំនួរ និង ចូលរួមជាមតិយោបល់ ការចែករំលែកបទពិសោធន៍ ដែលទាក់ទងនឹងការងារ ឬ ឧបសគ្គ ដើម្បីឈានរកនូវដំណោះស្រាយ ដើម្បីអភិវឌ្ឍន៍ចំណេះដឹងផ្ទាល់ខ្លួន ធ្វើអោយមានភាពងាយស្រួលក្នុងការអនុវត្តតួនាទីជាមេធាវីមានសំណួរទាំងមានដូចខាងក្រោមនេះ:

**ស១:** ច្បាប់អនុប្រយោគអ្នកណាជាអ្នកសម្រេច?

**ច១:** ច្បាប់អនុប្រយោគ គឺរាជរដ្ឋាភិបាលជាអ្នកសម្រេច ជាក់ស្តែងប៉ុន្មានខែមុននេះមានច្បាប់អនុប្រយោគមួយទើបតែចេញ។

**ស២:** ធម្មតាច្បាប់ចេញដោយរដ្ឋសភា ម៉េចបានច្បាប់អនុប្រយោគចេញដោយរដ្ឋាភិបាល?

**ច២:** ជាទូទៅច្បាប់ពិតជាចេញដោយរដ្ឋសភា ហើយឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រ លើកលែងតែច្បាប់អនុប្រយោគមួយនេះទេ។

**ស៣:** តើក្រៅបរិវេណវត្តអារាម ជាទ្រព្យរបស់វត្ត? សូមលើកឧទាហរណ៍

**ច៣:** ទីតាំងមួយចំនួនដែលនៅក្រៅបរិវេណវត្តក៏អាចជាទ្រព្យរបស់វត្តដែរ ដូចជា ឈាបនដ្ឋាន ដែលភាគច្រើនគេច្រើនធ្វើនៅក្រៅរបងវត្ត ឧទាហរណ៍ នៅវត្តភ្នំស្វាយក្នុងខេត្តរតនគីរីនេះ មានផ្លូវមួយក្រៅរបងវត្តទៅកន្លែងព្រះអង្គចូលព្រះនិពាន្ទ ដីកន្លែងនេះ គេចាត់ទុកថាជាដីវត្ត មិនមែនចាត់ទុកជាដីសាធារណៈរបស់រដ្ឋ ជាដីរបស់វត្តឱ្យតែបំរើវិស័យព្រះពុទ្ធសាសនា។

**ស៤:** អ្នកណាមានសិទ្ធិទិញដីឯកជនរបស់រដ្ឋ?

**ច៤:** គឺបុគ្គលគ្រប់រូបមានសិទ្ធិទិញដីឯកជនរបស់រដ្ឋ ឱ្យតែព្រមព្រៀងត្រូវរ៉ូវរឿងតម្លៃជាមួយរដ្ឋ។

**ស៥:** ច្បាប់ភូមិបាលចេញក្នុងឆ្នាំ ២០០១ អនុវត្ត ២០០៣ ចន្លោះពេលនេះមេឃុំស៊ីញ៉េលើលិខិតកាន់កាប់កម្មសិទ្ធិដីធ្លីដោយមិនដឹងថាគេអនុវត្តច្បាប់ថ្មីនេះទេ តើអ្នកស៊ីញ៉េនោះមានទោសឬទេ? បើការផ្សព្វផ្សាយច្បាប់នោះមិនទាន់ដល់ប្រជាពលរដ្ឋ តើអ្នកអនុវត្តខុស ឬការអ្នកដែលត្រូវផ្សព្វផ្សាយខុស?

**ច៥:** មេឃុំ គាត់មិនមានសិទ្ធិចេញវិញ្ញាប័ត្រកម្មសិទ្ធិដីធ្លីទេ គាត់គ្រាន់តែមានសិទ្ធិបញ្ជាក់ថាអ្នកណាជាម្ចាស់កម្មសិទ្ធិប៉ុណ្ណោះ ប៉ុន្តែឯកសារទាំងនេះ មិនមែនជាឯកសារដែលបញ្ជាក់ថា អ្នកនោះជាម្ចាស់កម្មសិទ្ធិទេ គឺវាគ្រាន់ជាឯកសារមួយដែលអាចភស្តុតាងជាភស្តុតាប៉ុណ្ណោះ ។ មានតែក្រសួងដែនដីនគរូបនីយកម្ម និង

សំណង់ប៉ុណ្ណោះ ដែលអាចចេញប័ណ្ណកម្មសិទ្ធិនោះបាន ។ ដូច្នេះ បើមានវិវាទកើតឡើង ឯកសារដែលមេឃុំចៅសង្កាត់ស៊ីញ៉េនេះ គ្រាន់តែជាភស្តុតាង ដែលគេដាក់ជូនតុលាការពិចារណាប៉ុណ្ណោះ។

**ស៦:** អ្វីទៅជាប័ណ្ណកម្មសិទ្ធិស្ថាពរ? និងអ្វីទៅជាវិញ្ញាប័ណ្ណប័ត្រសំគាល់អចលនវត្ថុ? តើពីរនេះខុសគ្នាដូចម្តេច?

**ច៦:** ប័ណ្ណកម្មសិទ្ធិស្ថាពរ គឺសំដៅលើភោគី ដែលគាត់ដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លីតាមរយៈមេភូមិ មេឃុំ រហូតដល់រដ្ឋបាលស្រុក ។ ដើម្បីបានប័ណ្ណកម្មសិទ្ធិស្ថាពរ គាត់ត្រូវគោរពលក្ខខណ្ឌ ៥ យ៉ាង ដូចជា កាន់កាប់ដោយ ពិតប្រាកដ គ្មានហិង្សា ដឹងលឺជាសាធារណៈ កាន់កាប់ដោយគ្មានអាក់ខានរយៈ ៥ ឆ្នាំ និង ដោយសុច្ឆរិត។ ភោគី គាត់មិនទាន់មានសិទ្ធិកម្មសិទ្ធិទេ ភោគី គឺខុសពីកម្មសិទ្ធិករដាច់ គឺគាត់សុំកាន់កាប់ដីជាក់ស្តែងលើដី ដោយធ្វើការស្នើសុំទៅភូមិបាលស្រុក ភូមិបាលស្រុកចេញបង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី ដែលបញ្ជាក់ពីភោគីស្របច្បាប់នៅលើដីនោះ គឺដើម្បីឈានទៅដល់ការទទួលបាននូវប័ណ្ណកម្មសិទ្ធិស្ថាពរ ។ ប្រសិនបើគាត់បំពេញតាមលក្ខខណ្ឌទាំងប្រាំខាងលើគ្រប់ហើយ ដូច្នេះគាត់សុំប័ណ្ណកម្មសិទ្ធិស្ថាពរបានហើយ ។ តែមិនមែនសុំភ្លាម បានភ្លាមទេ គឺត្រូវមានដំណើរការចុះអង្កេតវាស់វែងទៀត ដោយធ្វើកំណត់ហេតុអង្កេតដី ដែលត្រូវមានសាក្សីជាប់ព្រំដីមកផ្តិតមេដៃថា ដីនោះមិនជាន់លើដីរបស់គេទេ។ ហើយគេត្រូវបិទប្រកាសពី កំណត់ហេតុអង្កេតដីនោះ ដើម្បីឱ្យអ្នកដែលពាក់ព័ន្ធនឹងដីនោះមានសិទ្ធិជំទាស់ ប្រសិនបើដីនោះប៉ះពាល់ដល់ដីរបស់គេ ។ បើគ្មានអ្នកណាជំទាស់ទេ គឺគាត់អាចទទួលនូវបានប័ណ្ណកម្មសិទ្ធិស្ថាពរហើយ។

ចំណែកវិញ្ញាប័ត្រសំគាស់អចលនវត្ថុ គឺជាប័ណ្ណកម្មសិទ្ធិដែលធ្វើទៅតាមសម័យកាល ។

**ស៧:** អ្វីទៅដីចំណីផ្លូវ?

**ច៧:** ដីចំណីផ្លូវ ជាដីសាធារណៈរបស់រដ្ឋ ចំណែកចំងាយប៉ុន្មានពីផ្លូវ ដែលគេចាត់ទុកជាដីចំណីផ្លូវ គឺមានប្រកាសរបស់ក្រសួង ដែលកំណត់ទៅតាមទំហំផ្លូវនីមួយៗ។

**ស៨:** អ្វីទៅដីច្រាំងទន្លេ? ដីប៉ុន្មានគិតពីច្រាំង ទើបហៅដីច្រាំងទន្លេ? ដីប៉ុន្មានម៉ែត្រពីច្រាំងទន្លេ ដែលរដ្ឋមិនអាចធ្វើកម្មសិទ្ធិអោយ?

**ច៨:** ដីច្រាំងទន្លេ ជាដីសាធារណៈរដ្ឋ យើងមិនអាចកំណត់ថាដីប៉ុន្មានពីប៉ុន្មានពីទន្លេ ជាដីច្រាំងទន្លេនោះទេ គឺគេគិតពីកំរិតទឹកដែលខ្ពស់បំផុតនៅរដូវប្រាំង និងទាបបំផុតនៅរដូវវស្សា ។ បច្ចុប្បន្នយើងទាន់អាចកំណត់ថា

ប៉ុន្មានម៉ែត្រនៅឡើយ ព្រោះសព្វថ្ងៃក្រសួងដែនដី កំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពីការកំណត់អត្តសញ្ញាណពីប្រភេទដីទាំងនេះ។

**ស៩:** តើមានការសម្បទានដីណាមួយដែលទាក់ទងនឹងការកាន់កាប់ដីទេ បើគាត់បានដាំដើមស្វាយជាច្រើនដើមហើយ ទោះបីជាគាត់ចូលមកកាន់កាប់ដីនេះក្រោយឆ្នាំ ២០០១ ហើយក៏ដោយ?

**ច៩:** ជាគោលការណ៍ គឺគ្មានការទទួលបានសម្បទានដីណាមួយទេ ព្រោះច្បាប់ចាត់ទុកថាគាត់ជាមនុស្សចូលកាន់កាប់ដីនោះដោយខុសច្បាប់ទៅហើយ ។ ដូច្នេះច្បាប់មិនទទួលស្គាល់ការកាន់កាប់របស់គាត់ស្របច្បាប់ឡើយ ទោះបីជាការកាន់កាប់ក្រោយឆ្នាំ ២០០១ នោះ លើសពី ៥ ឆ្នាំក៏ដោយ។ ដូច្នេះ គ្មានសម្បានដីណាមួយសំរាប់គាត់ឡើយ ហើយបើតុលាការឱ្យគាត់រើចេញ គាត់ត្រូវតែរើចេញ ដោយមិនអាចទទួលបាននូវសំណងទេ ទោះបីជាគាត់បានដំណាំច្រើនប៉ុណ្ណា ឬសាងសង់អ្វីលើដីនោះក៏ដោយ។

**ស១០:** ប្រសិនបើមានអ្នកជិតខាងដាំដើមឈើលយចូលដីកម្មសិទ្ធិករមួយទៀត តើយើងអាចកាប់ ឬបះយកផលពីដើមឈើដែលលយចូលដីរបស់យើងបានដែរឬទេ?

**ច១០:** មាត្រា ៩១ នៃច្បាប់ភូមិបាល ចែងថាយើងអាចធ្វើបាន ។ តែជាគោលការណ៍ អនុវត្តជាក់ស្តែងវាអាចមានការព្រមព្រៀងពីម្ចាស់ព្រំដី ជួលកាលគាត់មិនបាច់កាប់ទេ តែអាចបះយកផលបរិភោគពីមែកដែលលយចូលមកបាន គឺអាស្រ័យទៅតាមការព្រមព្រៀងរបស់កម្មសិទ្ធិករ តែបើម្ចាស់ដើមឈើនោះមិនព្រមកម្មសិទ្ធិករដែលដើមឈើលយចូលអាចកាប់មែកដែលលយចូលមកបាន។

**ស១១:** ក្នុងករណីគ្រួសារមួយរៀបការហើយ អត់មានកូន ហើយប្រពន្ធស្ម័គ្រចិត្តព្រមឱ្យប្តីយកប្រពន្ធមួយទៀត តើភរិយាមានសិទ្ធិឱ្យប្តីយកប្រពន្ធម្នាក់ទៀត ដើម្បីបន្តពូជបានដែរទេ?

**ច១១:** ទោះបីជាគូភាគីព្រមព្រៀង ក៏ច្បាប់មិនអនុញ្ញាតិដែរ ការណ៏ដែលមិនអនុញ្ញាតិនេះ គឺក៏ក្នុងគោលបំណងមិនឱ្យប៉ះពាល់ដល់ប្រពៃណីល្អរបស់ប្រទេសយើង ។

**ស១២:** អ្នកខ្លះលែងលះគ្នាហើយ តើគាត់អាចត្រូវរ៉ូវគ្នាវិញបានទេ?

**ច១២:** ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩ មិនបានកំណត់ថាមិនឱ្យប្តីប្រពន្ធដែលលែងលះគ្នា ត្រូវរ៉ូវគ្នាវិញនោះទេ គឺបើគាត់ចង់រស់នៅជាមួយគ្នាវិញ គាត់អាចសុំចុះសំបុត្រអាពាហ៍ពិពាហ៍ថ្មីបាន។

**ស១៣:** គូស្វាមីភរិយាមួយគូរៀបការ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ តែពួកគេបានសុំច្បាប់រៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវ បានសុំលែងលះនៅតុលាការ តែម៉េចក៏តុលាការអោយឃុំ-សង្កាត់សម្រេចវិញដដែល?

**ច១៣:** បើគូស្វាមីភរិយានោះ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ គឺអាពាហ៍ពិពាហ៍នោះពុំមានលក្ខណៈស្របច្បាប់ទេ បើបញ្ជូនទៅតុលាការ តុលាការគ្មានសមត្ថកិច្ចឡើយ តុលាការនឹងបញ្ជូនអោយឃុំ-សង្កាត់ផ្សះផ្សាវិញ។

**ស១៤:** តើក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ និងក្រម ២០០៧ គេប្រើទាំងពីរ ?

**ច១៤:** ឥលូវនេះ ក្រមរដ្ឋប្បវេណី ២០០៧ គេមិនទាន់ប្រើបាននៅឡើយទេ រង់ចាំច្បាប់ដោយឡែកកំណត់ឱ្យប្រើ។ ដូច្នេះ ក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ នៅតែត្រូវបានប្រើប្រាស់ ព្រោះមិនទាន់មានច្បាប់ណាមួយនិរាករណ៍ក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ នេះនៅឡើយ។

**ស១៥:** កំជាប់ពាក្យត្រូវធ្វើជាលាយលក្ខអក្សរឬទេ? កន្លងមកមានតែហៅឱ្យចាស់ទុំដឹងលឺ។

**ច១៥:** ច្បាប់មិនតំរូវអោយធ្វើជាលាយអក្សរនោះទេ បើគាត់ចង់ធ្វើជាលាយលក្ខអក្សរ គាត់អាចធ្វើបាន។

**ស១៦:** តើជាគោលការណ៍ច្បាប់ តើមាត្រាណាមួយ ដែលកំណត់ថាអាចរៀបការបាន ដោយមិនចាំបាច់មានការព្រមព្រៀងជាមួយឪពុកម្តាយ?

**ច១៦:** គ្មានមាត្រាណាមួយដែលចែងថាអាចរៀបអាពាហ៍ពិពាហ៍បានដោយមិនចាំបាច់មានការព្រមព្រៀងពីឪពុកម្តាយនោះទេ គឺឱ្យតែពួកគាត់គោរពនូវលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទំរង់ដូចដែលមានចែងក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ដូចជាការបិទប្រកាសអាពាហ៍ពិពាហ៍ ដើម្បីប្រសិនបើគេឱ្យអាចប្តឹងជំទាស់បានប្រសិនបើមិនគោរពទៅតាមលក្ខខណ្ឌ។

**ស១៧:** បុរស ក និង នារី ខ ស្រលាញ់គ្នា តែឪពុកម្តាយខាងស្រីជំទាស់ ដោយឱ្យនារីរៀបការជាមួយបុរសផ្សេង ។ បុរសមានអាយុ ២៥ឆ្នាំ ហើយនារីនោះអាយុ ១៩ឆ្នាំ តើពួកគាត់អាចដឹកដៃគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍បានទេ?

**ច១៧:** បើតាមការអនុវត្តជាក់ស្តែង គឺបាន តែបើតាមផ្លូវច្បាប់ គឺមិនបាន ពីព្រោះ វាមានលក្ខខណ្ឌ ៣ លក្ខខណ្ឌទំរង់ ដូចជាការស្នើសុំអាពាហ៍ពិពាហ៍ ការបិទប្រកាសជាសាធារណៈ ដើម្បីឱ្យភាគីពាក់ព័ន្ធប្តឹងទាស់។ ការចុះសំបុត្រអាពាហ៍ពិពាហ៍ បើមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ គាត់ចុះឱ្យ ក៏យើងមិនដឹងថាម៉េចដែរ ប៉ុន្តែទោះជាយ៉ាងណា ច្បាប់ក៏ត្រូវតែគិតពីសីលធម៌ វាជាករណីផ្សេងទៀត។ ដូច្នេះ មន្ត្រីអត្រានុកូលដ្ឋានដែលគាត់សម្រេចចុះ ក៏មិនគិតថាខុសដែរ ពីព្រោះលក្ខខណ្ឌអាយុ គឺគ្រប់គ្រាន់ គ្រាន់តែខុសលក្ខខណ្ឌទំរង់តិចតួច ខ្ញុំគិតថាអាចធ្វើបាន។

**ស១៨:** បើជនជាតិឡាវ ឆ្លងមកទឹកដីកម្ពុជាហើយចង់រៀបការជាមួយនារីខ្មែរ តើអាចចុះសំបុត្រអាពាហ៍ពិពាហ៍បានទេ?

**ច១៨:** ជនជាតិឡាវនោះ បើគាត់ចង់រៀបអាពាហ៍ពិពាហ៍ជាមួយនារីខ្មែរ បុរសជនជាតិឡាវនោះ ត្រូវបញ្ជាក់ជាលិខិតពីអាជ្ញាធរឡាវពីភាពនៅលីវរបស់គាត់ និងលិខិតផ្សេងៗទៀត ហើយយកមកឆ្លងនៅក្រសួងការបរទេសកម្ពុជា ដោយក្រសួងការបរទេសកម្ពុជានឹងបញ្ជាក់ព័ត៌មាននោះជាមួយស្ថានទូតឡាវនៅកម្ពុជាទៀត ដើម្បីផ្ទៀងផ្ទាត់ថាតើព័ត៌មាននោះត្រឹមត្រូវ ឬមានការក្លែងបន្លំ ហើយក្រសួងការបរទេសនឹងបញ្ជូនលិខិតទាំងនោះ ទៅក្រសួងមហាផ្ទៃ ហើយក្រសួងមហាផ្ទៃនឹងបញ្ជូនលិខិតនោះទៅមន្ត្រីអត្រានុកូលដ្ឋានដែលនារី ឬបុរសនោះរស់នៅ បើលិខិតទាំងអស់មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គាត់អាចចុះសំបុត្រអាពាហ៍ពិពាហ៍បានហើយ ។

**ស១៩:** បុរសម្នាក់ ឬនារីម្នាក់ គាត់នៅបរទេស ហើយចង់រៀបការជាមួយជនជាតិខ្មែរ តែគាត់មិនបានបញ្ជាក់ពីភាពនៅលីវនៅស្រុកគាត់ទេ តែគាត់មានក្រុមហ៊ុននៅស្រុកខ្មែរ តើអាចបញ្ជាក់ពីភាពនៅលីវរបស់គាត់បានទេ?

**ច១៩:** ចំពោះការកសាងឯកសាររបស់ជនបរទេស មិនមែនជនជាតិខ្មែរ គឺគាត់ត្រូវតែបំពេញបែបបទជាទំរង់ទៅតាមនីតិវិធីច្បាប់របស់ប្រទេសគាត់ ទោះបីជាគាត់មានក្រុមហ៊ុននៅស្រុកខ្មែរមែនពិត តែក្រុមហ៊ុនឬស្ថាប័ននោះ មិនអាចកំណត់ពីលក្ខណៈបុគ្គលរបស់គាត់បានទេ ។ ដូច្នេះមានតែសមត្ថកិច្ចរដ្ឋរបស់គាត់ប៉ុណ្ណោះ ដែលអាចបញ្ជាក់បាន ។ គាត់ត្រូវធ្វើតាមច្បាប់ប្រទេសគាត់ ហើយបញ្ជូនមកក្រសួងការបរទេសកម្ពុជាផ្ទៀងផ្ទាត់ភាពត្រឹមត្រូវជាមួយស្ថានទូត ឬស្ថានកុងស៊ុលរបស់ប្រទេសគាត់នៅកម្ពុជា ហើយក្រសួងការបរទេស ឬស្ថានកុងស៊ុលនឹងបញ្ជូនលិខិតទាំងនេះទៅក្រសួងមហាផ្ទៃ ក្រសួងមហាផ្ទៃ នឹងបញ្ជូនមកមន្ត្រីអនុត្រាកូលដ្ឋានដែលគូស្រករថ្មីនឹងរៀបអាពាហ៍ពិពាហ៍ ។

**ស២០:** បើគាត់មិនបានបញ្ជាក់ពីភាពនៅលីវទេ តែគាត់បានរៀបការរួចទៅហើយ បើបានកូនបានចៅហើយ តើគាត់អាចចូលសញ្ជាតិបានទេ?

**ច២០:** ដើម្បីឱ្យអាពាហ៍ពិពាហ៍មួយស្របច្បាប់ គាត់ត្រូវគោរពនូវលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នៃប្រទេសកម្ពុជាសិន ។ ចុះបើអត់បានបញ្ជាក់លិខិតឱ្យបានត្រឹមត្រូវ តែអាជ្ញាធរគាត់អនុញ្ញាតិឱ្យរៀបការជាមួយគ្នាបានទេ? ចំលើយគឺ គាត់អាចធ្វើបានត្រឹមតែនៅភូមិឃុំទេ តែច្បាប់មិនអនុញ្ញាតិឱ្យគាត់ធ្វើទេ នៅពេលមានបញ្ហា ដូចនេះគាត់ត្រូវទទួលខុសត្រូវចំពោះច្បាប់ ព្រោះច្បាប់ហាមគាត់មិនឱ្យគាត់ធ្វើ ។ អញ្ចឹង ពេលមានកូន

មានចៅជារឿងមួយទៀត គឺ ការទទួលបានសញ្ជាតិមាន ៣ គឺ ទី ១. ការទទួលសញ្ជាតិតាមកំណើត ទី ២. តាមអាពាហ៍ពិពាហ៍ និងតាមសញ្ជាតូបនីយកម្ម ។ ប្រសិនបើពេលជនបរទេស ឬជនជាតិខ្មែរ រៀបការជាមួយគ្នា មានន័យថាគាត់អាចទទួលបានសញ្ជាតិខ្មែរហើយ លើកលែងតែគាត់មិនចង់បាន ប៉ុន្តែនៅក្នុងច្បាប់សញ្ជាតិខ្មែរយើងអាចមានសញ្ជាតិពីរ ទោះបីជាគាត់ទៅនៅអាមេរិក ចូលសញ្ជាតិអាមេរិកក៏ដោយ ក៏រដ្ឋខ្មែរយើងធានាមិនឱ្យពលរដ្ឋខ្មែរ បាត់បង់សញ្ជាតិខ្មែរដែរ ។ អញ្ចឹងគាត់មានកាតព្វកិច្ចចំពោះច្បាប់កម្ពុជាផង និងច្បាប់បរទេសដែលគាត់ទទួលបានសញ្ជាតិផង ។ តែប្រទេសមួយចំនួន មិនអនុញ្ញាតិឱ្យគាត់ទទួលបានសញ្ជាតិពីរនោះទេ គឺត្រូវបោះបង់សញ្ជាតិមួយសិន ។ ការឆ្លើយតបនឹងសំនួរៈ ការទទួលបានសញ្ជាតិជាលក្ខខណ្ឌទី ២ ទេ សំខាន់ធ្វើម៉េចឱ្យអាពាហ៍ពិពាហ៍របស់គាត់ស្របច្បាប់សិន។ ប្រសិនបើសំណុំឯកសារមិនបានបំពេញត្រឹមត្រូវដែលប្រទេសសាម៉ីបញ្ជាក់ឱ្យ តែអាជ្ញាធរយើងនៅតែស៊ីញ៉េឱ្យ នោះគឺគាត់ត្រូវទទួលខុសត្រូវខ្លួនឯង។

**ស២១:** បំរាមមិនឱ្យរៀបអាពាហ៍ពិពាហ៍ បុគ្គលគ្មានពលានុភាពនៃលឹង្គមិនអាចរៀបការបាន ចុះបើនារីមិនអាចមានកូនបានវិញ?

**ច២១:** ការពិតស្ត្រីដែលមិនអាចមានកូនបានក៏គួរតែចាត់ជាបំរាមមិនឱ្យរៀបអាពាហ៍ពិពាហ៍ដែរ ប៉ុន្តែការអនុវត្តជាក់ស្តែង គឺគេមិនគិតពីចំនុចនេះទេ។

**ស២២:** តើតុលាការមានច្បាប់សម្រាប់កាត់ទោសភាគីខាងស្រីទេ ប្រសិនបើភាគីខាងស្រីរៀបការថ្មីហើយបុរសជាប្តីនៅឆ្ងាយ តែមិនមានស្រីញីអីទេ ?

**ច២២:** ច្បាប់កំណត់ថា កាលណាប្តីប្រពន្ធនោះ បែកគ្នាអស់រយៈពេលជាង ១ឆ្នាំ គាត់អាចដាក់ពាក្យលែងលះ ហើយរៀបការថ្មីបាន។

**ស២៣:** បើនារីចង់រៀបការថ្មី ហើយបុរសជាប្តីមិនដឹងនៅទីណា បើសិនជានារីនោះដាក់ពាក្យប្តឹងទៅតុលាការ តើតុលាការអាចចេញដីកាស្វែងរកជននោះទេ?

**ច២៣:** ប្រសិនបើដឹងពីទីតាំងដែលគាត់រស់នៅ គេអាចដាក់ពាក្យបណ្តឹងទៅតុលាការរបស់ចុងចំលើយបាន ហើយគេអាចកាត់កំបាំងមុខគាត់បាន ប្រសិនបើកោះហើយចុងចំលើយនោះ ៣ ដងហើយ គាត់មិនចូល។ ដូច្នេះ តុលាការអាចចេញសាលក្រមកំបាំងមុខប្រកាសពីការបាត់ខ្លួនរបស់ចុងចំលើយដែលជាប្តី ហើយនារីនោះអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។

# ផ្នែកទី ៦

# ការវាយតំលៃ

# នៃ

# អង្គសិក្ខាសាលា



# ការវាយតំលៃនៃវគ្គសិក្ខាសាលា

## ១. ការវាយតំលៃ សិក្ខាសាលា

### ១.១. ការរៀបចំទូទៅនៃសិក្ខាសាលា

តាមរយៈការវាយតំលៃរបស់ដែលដកស្រង់ពីតារាងវាយតំលៃ សិក្ខាកាម ២៣% បានវាយតំលៃល្អខ្លាំង ៧៤% វាយតំលៃល្អ និង ៣% វាយតំលៃមធ្យម លើការរៀបចំទូទៅនៃអង្គសិក្ខាសាលានេះដែលនាំអោយសិក្ខាសាលាដំណើរការទៅយ៉ាងរលូន ។

### ១.២. ការសំរបសំរួលរបស់ក្រុមការងារ

២៦% នៃសិក្ខាកាមដែលចូលរួម បានធ្វើការវាយតំលៃល្អខ្លាំង ៧២% បានវាយតំលៃថាល្អ និង ២% បានវាយតំលៃមធ្យម លើការសំរបសំរួលរបស់ក្រុមការងារ ដែលជំរុញអោយកម្មវិធីនេះ មានសកម្មភាពផុសផុលទាំងវាគ្មិន និង អ្នកចូលរួម ។

## ២. ឯកសារ

៤៤% នៃការវាយតំលៃរបស់សិក្ខាកាម យល់ថាឯកសារដែលផ្តល់ជូនល្អខ្លាំង ៥១% វាយវាយតំលៃល្អ និង ៥% វាយតំលៃមធ្យម បើធៀបទៅ នឹងការធ្វើបទបង្ហាញរបស់វាគ្មិន ។

## ៣. ប្រធានបទ និង ខ្លឹមសារ

៩0% នៃសិក្ខាកាម យល់ថាប្រធានបទ និង ខ្លឹមសារមានប្រយោជន៍ខ្លាំង ដែលអាចជួយដល់ការដោះស្រាយវិវាទនៅក្នុងមូលដ្ឋានរបស់ពួកគាត់ និង ១0% វាយតំលៃថាមធ្យម ។

## ៤. ពេលវេលានៃបទបង្ហាញ និង ឱកាសសួររបស់សិក្ខាកាម

២៦%នៃសិក្ខាកាម បានវាយតំលៃល្អខ្លាំង ៤៩% វាយតំលៃថាល្អ និង ២៥% វាយតំលៃមធ្យម ចំពោះការកំនត់ពេលវេលានៃបទបង្ហាញ និង ការផ្តល់ឱកាសដល់សិក្ខាកាមដើម្បីសួរសំនួរ ក៏ដូចជាការចែករំលែកបទពិសោធន៍ពីសិក្ខាកាមដទៃទៀត ។

## ៥. រយៈពេលនៃសិក្ខាសាលា

៨៧% នៃសិក្ខាកាមដែលបានចូលរួមសិក្ខាសាលានេះ វាយតំលៃរយៈពេលនៃសិក្ខាសាលាមានរយៈពេលល្មម និង ១៣% វាយតំលៃថាមានរយៈពេលខ្លីពេក។

## ៦. ចំណេះដឹងរបស់វាគ្មិន

២១% នៃសិក្ខាកាមដែលបានចូលរួមសិក្ខាសាលានេះ វាយតំលៃចំណេះដឹងរបស់វាគ្មិនល្អខ្លាំង ៧៧% វាយតំលៃថាល្អ និង ២% វាយតំលៃថាមធ្យម ។

## ៧. អនុសាសន៍ដើម្បីកែលំអរដល់បទបង្ហាញរបស់វាគ្មិនសំរាប់សិក្ខាសាលាលើកក្រោយ

ជាមួយនឹងការវាយតំលៃលើវគ្គសិក្ខាសាលានេះ សិក្ខាកាមបានផ្តល់ជាអនុសាសន៍ដើម្បីកែលំអរដល់បទបង្ហាញរបស់វាគ្មិននីមួយៗ ដូចខាងក្រោម:

- សូមទុកពេលខ្លះៗ ចន្លោះពីប្រធានបទមួយទៅប្រធានបទមួយទៀត ដើម្បីអោយសិក្ខាកាមបានសួរទៅវាគ្មិននូវចំណុចដែលមានចម្ងល់ ។
- ការបង្ហាញរបស់វាគ្មិននីមួយៗ មិនលឿនពេក ក៏មិនយឺតពេក គួរទទួលយកបាន
- បទបង្ហាញរបស់វាគ្មិននីមួយៗបានច្បាស់លាស់ល្អ និងមានការអត់ធ្មត់ចំពោះការឆ្លើយពន្យល់ដល់សិក្ខាកាម ក្នុងបំណងចង់ឱ្យសិក្ខាកាមបានយល់ដឹងបានត្រឹមត្រូវក្នុងការដោះស្រាយបញ្ហាមូលដ្ឋាន។
- ដោយពេលវេលាក្នុងសិក្ខាសាលាខ្លីពេក វាគ្មិនទាំងអស់ពុំអាចពន្យល់លំអិតបាន។
- សូមវាគ្មិនដែលធ្វើបទបង្ហាញ ជួយរិះរកគំនិតល្អ និងការឧទ្ទេសនាមឱ្យកាន់តែល្អជាងនេះថែមទៀត។
- សូមបកស្រាយ និងសំរួលពាក្យពេចន៍ និងមាត្រាច្បាប់អោយសិក្ខាកាមងាយយល់។
- បទបង្ហាញរបស់វាគ្មិនល្អ អាចស្តាប់ទាន់ កត់ត្រាបាន ។
- សូមសរសើរដល់ការរៀបចំសិក្ខាសាលានេះ ។ ចំពោះវាគ្មិនសូមលើកឧទាហរណ៍ជាក់ស្តែងខ្លះ ដើម្បីបញ្ជាក់ដល់សិក្ខាកាមបានយល់ដឹងថែមទៀត។ ដោយឡែកខ្ញុំសំគាល់ឃើញថា លោកគ្រូ អ្នកគ្រូវ័យក្មេងឈ្លាសវៃ យល់ដឹងអំពីច្បាប់សមស្របជាក្រុមមេធាវី។
- ពេលវេលាខ្លីធ្វើអោយបទបង្ហាញ និងការចែករំលែកពីគ្នាទៅវិញទៅមកពុំបានល្អិតល្អន់ និងស៊ីជំរៅ។
- ពេលវេលាខ្លីពេក បកស្រាយមិនចប់។

- សូមកោតសរសើរដោយស្មោះចំពោះបទបង្ហាញរបស់ក្រុមមេធាវី ដែលបានលើកយកប្រធានបទប្រកបដោយខ្លឹមសារ និងអត្ថន័យសំខាន់ៗពាក់ព័ន្ធនឹងការដោះស្រាយវិវាទនៅមូលដ្ឋាន ពិសេសបញ្ហាដីធ្លី អាពាហ៍ពិពាហ៍ និងគ្រួសារ ដែលជាបញ្ហាជាអាទិភាព ដែលកើតមាននៅគ្រប់មូលដ្ឋាន និងស្របនឹងតួនាទីភារកិច្ចរបស់យើងខ្ញុំជាក្រុមប្រឹក្សាគ្រប់ថ្នាក់ ។
- ក្នុងការបកស្រាយបង្ហាញរបស់វាគ្មិននីមួយៗនៅសំនួរមួយ សូមអោយមានការប្រៀបធៀបផង ។
- សូមកោតសរសើរដោយស្មោះចំពោះបទបង្ហាញរបស់ក្រុមមេធាវីដែលបានលើកយកប្រធានបទប្រកបដោយខ្លឹមសារ និងមានអត្ថន័យសំខាន់ៗពាក់ព័ន្ធនៅនឹងវិវាទនៅក្នុងមូលដ្ឋាន និងស្របទៅនឹងតួនាទីភារកិច្ចរបស់យើងខ្ញុំជាក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ។
- សូមស្នើវាគ្មិនជួយផ្តល់ឯកសារផ្លូវការជាអំណះអំណាងដល់ខ្លឹមសារនៃមេរៀនមួយៗ ។ ឧទាហរណ៍ៈ យើងរៀនពីការលែងលះ សូមស្រង់វាក្យខណ្ឌទាក់ទងនឹងការលែងលះពីគ្រប់ច្បាប់ដែលកំពុងប្រើប្រាស់នៅកម្ពុជាបច្ចុប្បន្នផង ។
- ពេលសិក្ខាសាលាលើកក្រោយ សូមអោយវាគ្មិនធ្វើបទបង្ហាញឱ្យបានស៊ីជំរៅ ដោយភ្ជាប់នូវឧទាហរណ៍ដែលពាក់ព័ន្ធមកធ្វើការឆ្លុះបញ្ចាំង ដើម្បីឱ្យសិក្ខាកាមងាយយល់ និងចាប់បាននូវប្រធានបទដែលបានលើកឡើង ។
- គួរតែផ្តល់នូវបញ្ហាខ្លះដែលពាក់ព័ន្ធ និងកើតមានជាក់ស្តែង ហើយដោះស្រាយមិនបានតាមផ្លូវច្បាប់ ព្រោះមូលហេតុអ្វី?
- ការដោះស្រាយទៅតាមផ្លូវច្បាប់ វាងាយស្រួលណាស់ តែការរំលោភច្បាប់ដោះស្រាយមិនបាន ហើយនិងមានអយុត្តិធមិទៀតនោះ វានាំទៅដល់ការភ័យខ្លាច ឬជំនឿរបស់ប្រជាជននៅលើរដ្ឋបាល និងមិនជឿទៅលើច្បាប់ ។
- ការបង្ហាញរបស់វាគ្មិននីមួយៗបានបង្ហាញអំពីប្រធានបទនីមួយៗ ធ្វើអោយយើងខ្ញុំងាយយល់លើប្រធានបទនីមួយៗ ។
- បើអាចធ្វើបទបង្ហាញបាននូវការវិនិច្ឆ័យ ឬសវនាការរបស់រឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីណាមួយជាក់ស្តែងរបស់តុលាការខេត្តណាមួយ ទាក់ទងទៅនឹងមេរៀនទាំងនេះ ។
- នៅក្នុងប្រធានបទមួយសុំឱ្យមានលំហាត់សំខាន់ៗឱ្យបានច្រើន ។

- គួរមានឧទាហរណ៍សាមញ្ញៗ និងលំអិតឱ្យបានច្រើន ។ គួរបកស្រាយនិយមន័យនៃពាក្យមួយចំនួននៅក្នុងច្បាប់ដែលសិក្ខាកាមពុំសូវដែលឃើញ។
- សូមឱ្យវាគ្មិននីមួយៗ លើកឡើងនូវឧទាហរណ៍ជាក់ស្តែងយ៉ាងច្រើន ដើម្បីឱ្យសិក្ខាកាមយល់កាន់តែច្បាស់នូវច្បាប់ភូមិបាល និងច្បាប់វិវាទគ្រួសារ។
- សំណូមពរឱ្យក្រុមមេធាវីសិទ្ធ បើកវគ្គនេះឱ្យបានច្រើនបន្តទៀត ហើយសូមឱ្យគ្រូឧទ្ទេសនាមបកស្រាយឱ្យបានច្បាស់នូវខ្លឹមសារនីមួយៗ ព្រោះចំណុះខ្លះមិនទាន់ច្បាស់ តែភាគតិចទេ។
- សូមវាគ្មិនដែលធ្វើបទបង្ហាញជួយរិះរកគំនិតល្អ និងការឧទ្ទេសនាមឱ្យរិតតែល្អជាងនេះថែមទៀត។ សូមបកស្រាយ និងសំរួលពាក្យ និងមាត្រាច្បាប់ឱ្យសិក្ខាកាមងាយយល់។
- សិក្ខាសាលាល្អ
- សិក្ខាកាមបានចូលផ្លាស់ប្តូរយោបល់លើកនេះឃើញថាទទួលលទ្ធផលបានល្អ ពង្រីកការយល់ដឹងរបស់ពួកខ្ញុំជាសិក្ខាកាម
- អនុសាសន៍ និងបទបង្ហាញឃើញថាល្អ ក្នុងការរៀបចំក្តីឃើញថាល្អ គ្មានបញ្ហាអ្វីទេ
- អនុសាសន៍របស់អស់លោក លោកស្រីក្រុមមេធាវី ការបង្ហាញអំពីមេរៀននីមួយៗល្អប្រសើរ។

## ៨. សំនូមពរ

ស្របគ្នាជាមួយការវាយតំលៃនានា សិក្ខាកាមបានធ្វើការសំនូមពរដែលមានដូចជា:

- សមត្ថកិច្ចពាក់ព័ន្ធពុំបានចូលរួម (អាជ្ញាធរមូលដ្ឋាន, នគរបាល, កងរាជអាវុធហត្ថ) ដើម្បីពិភាក្សាជាមួយក្រុមប្រឹក្សា ពីព្រោះក្រុមប្រឹក្សា និងអាជ្ញាធរជាមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់គ្នា។
- សិក្ខាសាលាមានរយ:ខ្លីក៏ពិតមែន តែមានខ្លឹមសារសំខាន់សម្រាប់អ្នកអនុវត្តក្នុងមូលដ្ឋាន
- សុំបើកសិក្ខាសាលាអោយមានរយ:ពេលវែងជាងនេះ។
- បើកសិក្ខាសាលាលើកក្រោយៗទៀត ស្នើសុំរកទីកន្លែងដែលមានម៉ាស៊ីនត្រជាក់។ និងសុំវាគ្មិនប្រើមេក្រូនៅពេលឧទ្ទេសនាម
- សាលធ្វើសិក្ខាសាលាមានភាពក្តៅ បន្ទប់ទឹកមិនសមរម្យ ការវេចខ្ចប់ឯកសារមិនទាន់ធ្វើអោយមានភាពទាក់ទាញសិក្ខាកាមឱ្យមានចិត្តចង់យកមកមើលសារឡើងវិញ។ ឯកសារល្អមានតំលៃមានសារ:សំខាន់សម្រាប់មនុស្សគ្រប់រូប តែការវេចខ្ចប់មិនស្អាត មិនស្មើតំលៃឯកសារ។

- ការបញ្ចាំងស្លាយមិនសូវច្បាស់ មើលអក្សរឃើញព្រិល១ សូមកែសម្រួលអោយបានច្បាស់ល្អ ។
- សូមសិក្ខាសាលាលើកក្រោយធ្វើនៅខេត្តមណ្ឌលគីរីម្តង ។
- វគ្គក្រោយ សូមធ្វើនៅខេត្តមណ្ឌលគីរីម្តង ។
- ក្នុងសិក្ខាសាលានេះ បញ្ហាដែលបានជួបប្រទះពុំមានអ្វីគួរអោយកត់សំគាល់ឡើយ ការងារដែលប្រព្រឹត្តទៅបានល្អប្រសើរជាទូទៅ ។ សំណូមពរ សូមឱ្យសមាសភាពសិក្ខាកាមមានគណៈអភិបាលខេត្ត-ក្រុង-ស្រុកចូលរួម ព្រោះគណៈអភិបាលជាអ្នកអនុវត្តផ្ទាល់ក្នុងការដោះស្រាយវិវាទមូលដ្ឋានជាក់ស្តែងដូចជាគណៈកម្មការសុរិយោដីខេត្ត-ស្រុកដោះស្រាយជំលោះដីធ្លីខេត្ត-ស្រុក មានសមាសភាពគណៈអភិបាលក្នុងនោះដែរ ។
- សិក្ខាសាលាស្តីពីការដោះស្រាយវិវាទមូលដ្ឋន ដូចជាវិវាទដីធ្លី ច្បាប់ភូមិបាល និងច្បាប់អាពាហ៍ពិពាហ៍ រយៈពេល ២ ថ្ងៃនេះ គឺមានអត្ថន័យ និងចំបញ្ហាដែលមាននៅក្នុងមូលដ្ឋានផ្ទាល់ ។ ដូច្នេះសូមអោយក្រុមមេធាវីស៊ីវិទ្ធជួយនូវវគ្គបណ្តុះបណ្តាលបន្ថែមទៀត ពិសេសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់នៅទូទៅប្រទេស ។
- បរិមាណនៃសិក្ខាកាមបានចូលរួមសិក្ខាសាលាមានចំនួនតិចពេក ។ គួរឱ្យមានសិក្ខាកាមច្រើនជាងនេះចូលរួម ។ សិក្ខាសាលាស្តីពីការដោះស្រាយវិវាទមូលដ្ឋាន បើមានទៀត សូមឱ្យសិក្ខាកាមដដែលពេលនេះចូលរួមទៀត ។
- ក្នុងសិក្ខាសាលានេះមានការរៀបចំបានល្អ បានផ្តល់ឱកាសច្រើនសម្រាប់ទុកជាវាគ្មិនបានធ្វើបទបង្ហាញ និងការសម្របសម្រួលបានល្អ ។ សំណូមពរ បើមានសិក្ខាសាលាលើកក្រោយឱ្យមានការពិភាក្សាជាក្រុមចំរុះខេត្ត-ស្រុក ដើម្បីបានស្គាល់ និងមានភាពកាន់តែស្និតស្នាលរវាងសិក្ខាកាមដែលមកពីខេត្តនានា ។
- សំណូមពរសូមក្រុមមេធាវីបន្តវគ្គបណ្តុះបណ្តាលនេះជាបន្តទៅទៀត ។
- សុំផ្តល់ឯកសារច្បាប់ដែលពាក់ព័ន្ធប្រធានបទដែលបានបង្ហាញ
- សូមបញ្ជាក់តាមមេរៀននីមួយ១ ឱ្យយឺតបន្តិច ដើម្បីយើងខ្ញុំយល់បានល្អ ។
- សំណូមពរសម្រាប់សិក្ខាកាមនូវពេលក្រោយ មេត្តារៀបចំសៀវភៅទៅតាមស្លាយបញ្ចាំង

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

១. តារាងកម្មវិធី នៃ អង្គសិក្ខាសាលា

២. ឯកសារមេរៀនរបស់លោក វ៉ាន់ និមល

៣. ឯកសារមេរៀនរបស់លោកស្រីមេធាវី សាត ធីតា

៤. ឯកសារមេរៀនរបស់លោកមេធាវី អ៊ឹម ផាន់ណា

៥. បញ្ជីវត្តមានអ្នកចូលរួម